**Jean-Michel Filippi**

**Hiep Chan Vicheth**

# វចនានុក្រមបញ្ចេញសូរសំឡេងភាសាខ្មែរ

ភាសាខ្មែរស្តង់ដា និងគ្រាមភាសាភ្នំពេញ

# Khmer pronouncing dictionary

Standard Khmer and Phnom Penh dialect

# Dictionnaire de la prononciation du Khmer

Khmer standard et Phnompenhois

KAM éditions

Phnom Penh

2016

UNESCO

**Jean-Michel Filippi**
**Hiep Chan Vicheth**

# វចនានុក្រមបញ្ចេញសូរសំឡេងភាសាខ្មែរ

ភាសាខ្មែរស្តង់ដា និងគ្រាមភាសាភ្នំពេញ

# Khmer pronouncing dictionary

Standard Khmer and Phnom Penh dialect

# Dictionnaire de la prononciation du Khmer

Khmer standard et Phnompenhois

Phnom Penh
2016

# បុព្វកថា

ការរៀបចំតាក់តែងជាវចនានុក្រមបញ្ចេញសូរសំឡេងភាសាខ្មែរស្តង់ដារនេះបានចោទជាសំណួរផ្សេងៗជាច្រើនដូចជា ៖ "តើមានការទទួលស្គាល់ថាមានការបញ្ចេញសំឡេងភាសាខ្មែរស្តង់ដារហើយឬនៅ? តើភាសាខ្មែរស្តង់ដារមានលក្ខណៈយ៉ាងដូចម្តេចខ្លះ? តើភាសាខ្មែរស្តង់ដារមានប្រភពមកពីណា?" យើងគប្បីយល់អំពីសញ្ញាណនៃ "ភាសាស្តង់ដារ" ជាមុនសិន។ នៅក្នុងវចនានុក្រមនេះ "ភាសាស្តង់ដារ" មិនសំដៅទៅលើក្បួនច្បាប់នៃភាសា ដូចន័យធម្មតាដែលគេធ្លាប់ផ្តល់អោយពាក្យនេះទេ។ សម្រាប់ពួកយើង ពាក្យថា "ភាសាស្តង់ដារ"សំដៅទៅលើរបៀបដែលភាសាខ្មែរត្រូវបាន ឬគួរត្រូវបានប្រើប្រាស់នៅក្នុងបរិបទផ្លូវការណាមួយដូចជា៖ នៅតាមសាកលវិទ្យាល័យនានា សាលារៀនផ្សេងៗ នៅក្នុងផ្នែករដ្ឋបាល នៅតាមបណ្តាញសារព័ត៌មាន ។ល។

គេមិនសូវគិតដល់ភាពសមហេតុផលនៃសំណួរទាំងប៉ុន្មាននេះទេ ដោយហេតុថាភាសាខ្មែរទាំងអស់បានបង្ហាញពីឯកភាពមួយរួចស្រេចទៅហើយ។ដូច្នេះភាពប្រែប្រួលបែបភូមិសាស្ត្រភាសាវិទ្យាក៏ត្រូវបានគេចាត់ទុកថាជារឿងបន្ទាប់បន្សំ។

តាមលោក Huffman (១៩៦៧) ៖ "គ្រាមភាសាទាំងឡាយនៅប្រទេសកម្ពុជាមានលក្ខណៈសភាគនឹងគ្នាខ្លាំងណាស់ ហើយកម្រិតនៃភាពប្រែប្រួលនៃគ្រាមភាសាខ្មែរប្រហាក់ប្រហែលទៅនឹងកម្រិតនៃភាពប្រែប្រួលនៃគ្រាមភាសាអង់គ្លេសនៅអាមេរិក។ សូម្បីតែគ្រាមភាសាខ្មែរនៅភាគខាងល្ងសាននៃប្រទេសថៃ និងគ្រាមភាសាខ្មែរនៅភាគអាគ្នេយ៍នៃប្រទេសវៀតណាម ក៏អាចយល់គ្នាទៅវិញទៅមកបានជាមួយនឹងគ្រាមភាសានៅប្រទេសកម្ពុជាដែរ។ ចំណែកឯលក្ខណៈខុសប្លែកគ្នារវាងគ្រាមភាសាទាំងនេះវិញ គឺវាប្រហាក់ប្រហែលគ្នាទៅនឹងភាពខុសគ្នារវាងភាសាអង់គ្លេសនៅប្រទេសអង់គ្លេស និងភាសា

អង់គ្លេសនៅអាមេរិកយ៉ាងដូច្នោះដែរ។"

បញ្ហាដែលយើងលើកឡើងនេះ គឺនៅត្រង់ភាពមិនច្បាស់លាស់ទាក់ទងនឹងពាក្យ "សភាគ" និង ពាក្យថា "យល់គ្នាទៅវិញទៅមក" (Filippi, ២០០៧) ។ យើងបានដឹងហើយថា ការអះអាងរបស់លោក Huffman គ្មានភស្តុតាងណាជាក់ស្ដែងនោះទេ។ ក្រៅពីការអង្កេតស្រាវជ្រាវមួយចំនួនតូចអំពីភាសាខ្មែរនៅតាមតំបន់ផ្សេងៗ (Filippi, ២០០២) យើងមិនមានការពណ៌នាណាមួយច្បាស់លាស់អំពីភាពប្រែប្រួលបែបភូមិសាស្ត្រភាសាវិទ្យានៃភាសាខ្មែរនោះទេ។

# ១. ការលេចចេញនៃការបញ្ចេញសូរសំឡេងភាសាខ្មែរស្តង់ដារ

## ១.១. មុនសម័យទំនើប

ចាប់តាំងពីសតវត្សទី ១៤ រហូតមកដល់មុននេះមិនយូរប៉ុន្មាន វត្តអារាមស្ទើរតែជាកន្លែងតែមួយគត់សម្រាប់រៀបចំតាក់តែងសរសេរអត្ថបទ។ នៅតាមទីវត្តអារាមនីមួយៗ គេមានរបៀបសរសេរអត្ថបទរៀងៗខ្លួន ដោយផ្អែកលើមូលដ្ឋាននៃការបញ្ចេញសំឡេងតាមតំបន់ដែលពួកគេឋិតនៅ។ក្នុងចំណោមទីវត្តអារាមទាំងអស់ យើងមិនឃើញមានទីវត្តអារាមណាមួយ ដែលគេអាចកំណត់បានថាជាមជ្ឈមណ្ឌលតែមួយ ដែលអាចប្រមូលផ្តុំជាក្បួនខ្នាតទូទៅ សម្រាប់ឲ្យវត្តអារាមផ្សេងៗទៀតទទួលយក ឬធ្វើតាមនោះទេ។

តាមលោក Maspero (១៩១៥) ដែលជាអ្នកចងក្រងសៀវភៅវេយ្យាករណ៍ខ្មែរសម័យទំនើបលើកទី ១ លោកបានលើកឡើង៖ "រហូតមកដល់ពេលនេះ នៅមិនទាន់មានអ្នកណាមកកំណត់អក្ខរាវិរុទ្ធអោយបានច្បាស់លាស់នៅឡើយទេ ហើយរឿងអក្ខរាវិរុទ្ធនេះគឺវាទៅតាមអ្នកដែលសរសេរចម្លងអត្ថបទ ដែលត្រូវបានគេចាត់ទុកថាជាអ្នកចេះដឹងនៅប្រទេសកម្ពុជា។"

ទោះមកដល់បច្ចុប្បន្ននេះហើយក៏ដោយ ក៏គេនៅឧស្សាហ៍ឮពីមនុស្សវ័យចំណាស់ខ្លះថា ពួកគាត់អាចអានតែច្បាប់(ច្បាប់អំពីក្រមសីលធម៌) ដែលគេសរសេរនៅទីវត្តអារាម នៅនឹងភូមិស្រុកដែលពួកគាត់រស់នៅតែប៉ុណ្ណោះ។

## ១.២. អត្ថបទពណ៌នាដំបូងៗអំពីភាសាវិទ្យានៃភាសាខ្មែរ

អត្ថបទភាសាវិទ្យាដំបូងៗត្រូវបានគេសរសេរឡើងនៅសម័យអាណានិគមបារាំង(១៨៦៣-១៩៥៣)និងនៅសម័យសង្គមរាស្ត្រនិយម (១៩៥៥-១៩៧០) ។ អត្ថបទទាំងនេះបានប្រាប់ឲ្យយើងដឹងអំពីបែបបទ

នៃការបញ្ចេញសូរសំឡេងភាសាខ្មែរ ដែលគេទទួលស្គាល់ថាជាការបញ្ចេញសូរសំឡេងដែលត្រឹមត្រូវមួយ ប៉ុន្តែវាមិនមែនជាការបញ្ចេញសូរសំឡេងតាមបែបស្តង់ដារនោះទេ។

នៅក្នុងអត្ថបទរបស់លោក Finot (១៩០២) និង អត្ថបទរបស់លោក Maspero (១៩១៥) មានពត៌មានគួរឲ្យចាប់អារម្មណ៍ជាច្រើន ប៉ុន្តែអត្ថបទទាំងនេះមិនបានបញ្ជាក់ថា ភាសាដែលគាត់បានសិក្សាជាគ្រាមភាសាណាមួយដែលមានការបញ្ចេញសំឡេងមួយដែលអាចចាត់ទុកថាល្អនោះទេ។

សេចក្តីពណ៌នារបស់លោក Martini (១៩៤៦) គឺជាអត្ថបទទី ១ ដែលបានបញ្ជាក់អំពីគ្រាមភាសាខ្មែរមួយច្បាស់លាស់ដែលគាត់បានសិក្សា គឺគ្រាមភាសាភ្នំពេញ។ ជម្រើសនៃការពណ៌នាអំពីគ្រាមភាសាភ្នំពេញនេះ មិនមែនដោយសារគ្រាមភាសាភ្នំពេញល្អជាងគ្រាមភាសាខ្មែរដទៃផ្សេងនោះទេ។ លោក Martini បានពន្យល់យ៉ាងដូច្នេះ៖ "យើងជ្រើសរើសការបញ្ចេញសូរសំឡេងនៃគ្រាមភាសាមួយ ដែលស្ថិតនៅរវាងគ្រាមភាសាខ្មែរខេត្តបាត់ដំបងដែលមានលក្ខណៈអភិរក្ស និងគ្រាមភាសាខ្មែរនៅកូសាំងស៊ីនដែលមានការធ្វើស្រៈផ្សំពីរនីយកម្ម។"

រឿងទាំងអស់នេះត្រឹមត្រូវតែមួយផ្នែកប៉ុណ្ណោះ ដោយសារហេតុផលដូចខាងក្រោម ៖

ក. នៅសម័យនោះ នៅរាជធានីភ្នំពេញសំបូរជនជាតិចិនច្រើន ហើយភាសាចិនទាជីវត្រូវបានគេនិយាយច្រើនជាងភាសាខ្មែរ។

ខ. បន្ទាប់ពីពិនិត្យមើលឲ្យច្បាស់លើសេចក្តីពណ៌នារបស់លោក Martini យើងសង្ស័យថា ការបញ្ចេញសូរសំឡេងដែលលោកបានពណ៌នានោះអាចមានដើមកំណើតពីគ្រាមភាសាមួយនៅខេត្ត (ខេត្តកំពង់ស្ពឺ?) ច្រើនជាង។ យើងបានសង្កេតឃើញនៅក្នុងសេចក្តីពណ៌នានោះអំពីអវត្តមាននៃស្រៈផ្សំពីរនីយកម្ម ដែលមានក្នុងភាសាខ្មែរភាគកណ្តាល។ ឧទាហរណ៍ដូចជា ពាក្យ "កោរ" មានការបញ្ចេញសំឡេងថា [kaɔ] នៅខ្មែរកណ្តាល ប៉ុន្តែនៅភូមិមួយចំនួននៅក្បែរទីរួមខេត្ត

កំពង់ស្ពឺ មានការបញ្ចេញសំឡេងថា [ko:]។ ហេតុផលដ៏ច្បាស់លាស់មួយទៀត គឺរាល់អ្នកនិយាយដែលលោក Martini បានជ្រើសរើសយកមកធ្វើការសិក្សា គឺជាព្រះសង្ឃដែលមកពីតំបន់ផ្សេងៗគ្នានៃប្រទេសកម្ពុជា។ នៅទសវត្សឆ្នាំ ១៩៣០ រាជធានីភ្នំពេញបានក្លាយជាមជ្ឈមណ្ឌលសាសនាដ៏សំខាន់មួយ ដោយសារមានការបង្កើតជាពុទ្ធសាសនបណ្ឌិតឡើងនៅឆ្នាំ ១៩៣០។

គ. សេចក្តីពណ៌នានេះក៏បានបង្ហាញដែរថាសំណេរភាសាខ្មែរបានមានឥទ្ធិពលយ៉ាងខ្លាំងទៅលើការស្តាប់ឮរបស់លោក Martini និងអ្នកនិយាយទាំងអស់របស់គាត់។ យើងអាចសង្កេតរឿងនេះបានតាមរយៈវត្តមាននៃសូរព្យញ្ជនៈរនាំងក្រអូមនៅបន្ទាប់ពីស្រៈមុខដែលមិនមែនជាទិដ្ឋភាពនៃភាសាខ្មែរកណ្តាលនោះទេ។ ឧទាហរណ៍ដូចជាពាក្យ "គេង"។ ការបញ្ចេញសូរសំឡេងចំពោះពាក្យនេះ គឺ [ke:ɲ] មិនមែនបញ្ចេញសូរសំឡេងថា [ke:ŋ] នោះទេ ទោះបី ជាពាក្យនេះសរសេរនឹងអក្សរ "ង" ក៏ដោយ។ សំណេរព្យញ្ជនៈ "ង" មានការបញ្ចេញសំឡេង [ŋ] នៅក្នុងបរិបទផ្សេងពីនេះ។

សេចក្តីពណ៌នារបស់លោក Martini គឺជាអ្វីដែលនៅប្រមាណ ២ ឬ ៣ ឆ្នាំក្រោយមក បានក្លាយជាការបញ្ចេញសំឡេងស្តង់ដារដែលមានលក្ខណៈដូចខាងក្រោម ៖

- ជាភាសាដែលប្រើប្រាស់ដោយបញ្ញាវន្ត ជាពិសេសអ្នកដែលមកពីវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត។
- ជាឥទ្ធិពលដ៏ខ្លាំងក្លាមួយរបស់សំណេរភាសាខ្មែរទៅលើការបញ្ចេញសូរសំឡេង។

## ១.៣. ការលេចចេញយ៉ាងយឺតៗនៃបទដ្ឋានភាសាខ្មែរ

នៅទសវត្សឆ្នាំ ១៩៥០ ភាសាខ្មែរស្តង់ដារបានលេចឡើងយ៉ាងយឺតៗ។ សញ្ញាណនៃ "ការបញ្ចេញសំឡេងល្អ" បានក្លាយទៅជា

តថភាពសង្គមមួយ បើទោះជានៅសម័យនោះគ្មានអត្ថបទណាបានបង្ហាញពីវិធី ឬក្បួនច្បាប់នៃការបញ្ចេញសូរសំឡេងល្អក៏ដោយ។

អ្វីដែលគួរឲ្យចាប់អារម្មណ៍នៅត្រង់នេះ គឺថាភាសាខ្មែរស្តង់ដារថ្មីមួយបានប្រាកដខ្លួនឡើង។ នោះគឺការបញ្ចេញសូរសំឡេងរបស់មនុស្សដែលមានការអប់រំខ្ពង់ខ្ពស់ និងបញ្ញវន្ត ដែលជាអ្នកដែលបានលុបបំបាត់របៀបបញ្ចេញសូរសំឡេងកំណើតនៅតាមតំបន់របស់ពួកគេម្នាក់ៗ ហើយងាកមកខិតខំបង្កើតការបញ្ចេញសូរសំឡេងដែលត្រូវនឹងសំណេរទៅវិញ។ លទ្ធផលនៃក្បួនច្បាប់នេះបានធ្វើឲ្យភាសាចាកចេញពីភាពដើម។

ឧទាហរណ៍ដ៏ល្អបំផុតទាក់ទងនឹងអ្វីដែលជាក្បួនច្បាប់នោះ គឺមានដូចអ្វីដែលលោកស្រី Henderson (១៩៥២) បានសរសេរក្នុងស្នាដៃរបស់គាត់ក្រោមចំណងជើងថា "លក្ខណៈពិសេសនៃការបញ្ចេញសូរសំឡេងនៃភាសាខ្មែរ (The Main Features of Cambodian Pronunciation)"។

បើមើលលើស្នាដៃលោកស្រី Henderson (១៩៥២) សូរស័ព្ទស្រៈក្នុងភាសាខ្មែរគួរតែត្រូវបានចាត់ថ្នាក់ទៅតាមលក្ខណៈផ្ទុយគ្នារវាងសំឡេងធម្មតា (Modal Voice) និងសំឡេងថ្លុំ (Breathy Voice)។

រឿងនេះជារឿងត្រឹមត្រូវនៅប៉ុន្មានសតវត្សមុន ប៉ុន្តែវាមិនមែនជាទិដ្ឋភាពនៃភាសាខ្មែរនាពេលបច្ចុប្បន្ននេះទេ។ សំឡេងថ្លុំជាផ្នែកមួយនៃដំណើរការអឃោសកម្មនៃសូរ ដែលកើតមាននៅក្នុងភាសាខ្មែរចាប់តាំងពីសតវត្សទី១៥មកម្ល៉េះ។ទាក់ទងនឹងដំណើរការអឃោសកម្មនេះ យើងអាចលើកយកពាក្យ "ទា" មកធ្វើជាឧទាហរណ៍បាន។ តារាងខាងក្រោមនឹងបង្ហាញពីការវិវត្តនៃការបញ្ចេញសូរសំឡេងនៃពាក្យ "ទា" (សញ្ញា ̤ នៅពីក្រោមបញ្ជាក់ថាជាសំឡេងថ្លុំ) ៖

| **ពាក្យ** | **សម័យកាលទី១** | **សម័លកាលទី២** | **សម័យកាលទី៣** |
|---|---|---|---|
| ទា | [daː] | [d̤ɛ̤a̤] | [tiɜ] |

តារាងខាងលើនេះបង្ហាញថាព្យញ្ជនៈឃោសៈ [d] បានក្លាយទៅជាព្យញ្ជនៈអឃោសៈ [t] ដោយឆ្លងកាត់ដំណើរការមួយ ដែលក្នុងនោះមានការផ្លាស់ប្តូរទៅជាសម្លេងផ្លុំ [d̤] និងការប្រែប្រួលនៃស្រៈ ៖ ពីស្រៈ [a] ទៅជា [ɛ̤a̤] រួចក្រោយមកក៏ក្លាយទៅជា [iɜ]។ យើងអាចមើលឃើញឥទ្ធិពលនៃបាតុភូតទាំងនេះ ដែលគេហៅថាបម្រែបម្រួលអំបូរភាសាមន-ខ្មែរ (Mon-Khmer Shift) នៅក្នុងប្រព័ន្ធស្រៈខ្មែរបច្ចុប្បន្នបាន ដោយពិនិត្យលើទំនាក់ទំនងរបស់វាជាមួយនឹងប្រព័ន្ធសំណេរភាសាខ្មែរ។ មានរឿងមួយដែលយើងប្រាកដច្បាស់ គឺថានាពេលសព្វថ្ងៃនេះ ឬក៏កាលពីទសវត្សឆ្នាំ ៥០ មិនមានគ្រាមភាសាខ្មែរកណ្តាលណាមួយដែលយករបៀបផ្ទុយគ្នារវាងសំឡេងធម្មតានិងសំឡេងផ្លុំជារចនាសម្ព័ន្ធនោះទេ។

ទស្សនៈរបស់លោកស្រីHendersonអំពីភាសាខ្មែរពិតជាត្រឹមត្រូវប្រសិនបើយើងផ្អែកទៅលើទិដ្ឋភាពប្រវត្តិភាសាខ្មែរ ប៉ុន្តែបញ្ហាមួយដែលគួរឲ្យកត់សម្គាល់នោះ គឺនៅត្រង់ថាភាសាខ្មែរដែលលោកស្រីពណ៌នានោះមិនបានស្តែងពីតថភាពនៃការបញ្ចេញសូរសំឡេងភាសាខ្មែរនៅទសវត្សឆ្នាំ ៥០ នោះទេ។ មូលហេតុគឺងាយយល់ទេ។ អ្នកនិយាយដែលលោកស្រីបានជ្រើសរើសយកមកធ្វើការសិក្សា គឺលោកកេង វ៉ាន់សាក់ ដែលជាអ្នកប្រាជ្ញខ្មែរដ៏មានឥទ្ធិពលម្នាក់លើវិស័យអក្សរសាស្ត្រ ភាសា និងអរិយធម៌ខ្មែរ។ លោកកេង វ៉ាន់សាក់ បានសរសេរសៀវភៅមួយក្បាល ដែលមានចំណងជើងថា ៖ "មូលភាពនៃការបង្កើតពាក្យថ្មី"។ ក្នុងនាមជាអ្នកនិយាយ លោកកេងវ៉ាន់សាក់មិនបានប្រើប្រាស់សូរសំឡេងគ្រាមភាសាខ្មែរខេត្តកំពង់ឆ្នាំងរបស់គាត់នោះទេ។ ផ្ទុយទៅវិញ សូរសំឡេងដែលគាត់បានប្រើប្រាស់ គឺជាសូរសំឡេងមួយដែលមានក្បួនច្បាប់ ហើយដែលទទួលឥទ្ធិពលយ៉ាងច្រើនពីសំណេរនៃភាសាខ្មែរ។

ឧទាហរណ៍មួយផ្សេងទៀត គឺជាស្នាដៃរបស់លោក ឃួន សុខម្ភូ ដែលបានសរសេរក្នុងនិក្ខេបបទថ្នាក់បណ្ឌិតរបស់លោក នៅទី

ក្រុងប៉ែកឡាំង ក្នុងឆ្នាំ ១៩៦៧។ លោក ឃួន សុខម្ភ បានវិភាគអំពីការបញ្ចេញសូរសំឡេងភាសាខ្មែរ ដោយយកការបញ្ចេញសូរសំឡេងរបស់សម្ដេចព្រះសង្ឃរាជ ជួន ណាត ជាមូលដ្ឋាន។ ចំណែកឯលោក Gorgonijev វិញ ក៏បានសរសេរអំពីវេយ្យាករណ៍ភាសាខ្មែរដែរ នៅឆ្នាំ ១៩៦៦ ហើយអ្នកនិយាយរបស់គាត់មានតែមួយរូបគត់ គឺលោកសាស្ត្រាចារ្យបណ្ឌិត ឡុង សៀម។

ការកំណត់ពីមូលដ្ឋាននៃការបញ្ចេញសូរសំឡេងក្នុងភាសាខ្មែរ ដោយផ្អែកតែទៅលើការបញ្ចេញសូរសំឡេងរបស់មនុស្សសំខាន់ណាម្នាក់ដែលបានទទួលការអប់រំ គឺស្ទើរតែគ្មានអ្វីដែលអាចបង្ហាញអំពីតថភាពជាក់ស្ដែងនៃការបញ្ចេញសូរសំឡេងនៃភាសាខ្មែរប្រចាំថ្ងៃបាននោះទេ។

សរុបសេចក្ដីមក យើងអាចចាត់ទុកថាភាសាខ្មែរស្តង់ដារ ឬភាសាដែលអាចចាត់ទុកថាមានកម្រិតស្តង់ដារ មិនមាននៅទីតាំងភូមិសាស្ត្រណាមួយច្បាស់លាស់នោះទេ។ អត្ថបទទាំងឡាយដែលបានបោះពុម្ពនៅក្នុងកំឡុងពេលនោះសុទ្ធតែមានលក្ខណៈដូចៗគ្នា គឺថាអ្នកនិយាយភាសាខ្មែរម្នាក់ៗដែលអ្នកស្រាវជ្រាវទាំងនោះបានជ្រើសរើសយកមកសិក្សាសុទ្ធសឹងតែជាអ្នកដែលមានចំណេះដឹងជ្រៅជ្រះ ហើយមានការបញ្ចេញសូរសំឡេងដោយផ្អែកលើសំណេរជាមូលដ្ឋាន។

## ២. ភាសាខ្មែរសហសម័យ

នៅថ្ងៃទី១៩ខែមេសា១៩៧៥ ទីក្រុងទាំងអស់នៃប្រទេសកម្ពុជាបានក្លាយជាទីក្រុងរហោឋាន ស្ងាត់ជ្រងំ គ្មានមនុស្សម្នានោះទេ។ ប្រជាជនទីក្រុងទាំងអស់ត្រូវបានជម្លៀសចេញពីទីក្រុងទៅកាន់ជនបទស្រុកស្រែ ហើយការអប់រំក៏ត្រូវបានហាមឃាត់ដែរ។ បន្ទាប់ពីការដួលរលំនៃរបបប្រល័យពូជសាសន៍ខ្មែរក្រហម ស្ថានភាពសង្គមខ្មែរបានវិលត្រឡប់មករកសភាពធម្មតាវិញ ហើយជីវភាពទីក្រុងក៏បានរីកលូតលាស់ឡើងវិញយ៉ាងឃើតៗដែរ។

នៅក្នុងបរិបទនៃការរៀបចំកសាងប្រទេសឡើងវិញនៅកំឡុងទសវត្សឆ្នាំ ៨០ ការដែលថាមានការលេចឡើងនៃភាសាខ្មែរស្តង់ដារ ហាក់ដូចជាមិនត្រឹមត្រូវទេ។

នៅក្រោមការគ្រប់គ្រងនៃរបបខ្មែរក្រហម ប្រជាជនខ្មែរបានរងទុក្ខលំបាកយ៉ាងខ្លាំង ដោយសារតែខ្មែរក្រហមបានដាក់កំហិតលើជីវភាពរស់នៅរបស់ប្រជាជន។ សូម្បីតែការប្រើប្រាស់ភាសារបស់ពួកគេក៏បិតនៅក្រោមកំហិតដ៏ឃោរឃៅនេះដែរ។ របៀបនិយាយរបស់មនុស្សមួយចំនួនបានធ្វើអោយពួកខ្មែរក្រហមចាត់ទុកពួកគេថាជាសត្រូវវណ្ណៈ។

នៅប៉ុន្មានឆ្នាំក្រោយពីការដួលរលំនៃរបបខ្មែរក្រហម ហើយរហូតមកដល់សព្វថ្ងៃនេះនៅតែមិនមានអត្ថបទច្បាស់លាស់ណាមួយដែលពន្យល់បកស្រាយបញ្ជាក់ និងគ្មានការលើកឡើងឲ្យប្រាកដប្រជាណាមួយអំពីការបញ្ចេញសូរសំឡេងស្តង់ដារនោះទេ។ ប៉ុន្តែការរីកលូតលាស់របស់ទីក្រុងបានធ្វើឲ្យការបញ្ចេញសូរសំឡេងស្តង់ដារនៃភាសាខ្មែរលេចចេញជារូបរាងឡើងឃើតៗ។

## ២.១. ការអង្កេតពីការបញ្ចេញសូរសំឡេងភាសាខ្មែរស្តង់ដារ

ដើម្បីប្រមូលទិន្នន័យនៃវចនានុក្រមការបញ្ចេញសូរសំឡេងភាសាខ្មែរនេះ យើងបានសិក្សា និងសាកល្បងលើអ្វីដែលជាសញ្ញាណនៃការបញ្ចេញសំឡេងដែលល្អ និងដែលគេចង់បាន។

យើងក៏បានធ្វើការជ្រើសរើសអ្នកនិយាយជាច្រើននាក់ ដែលធ្វើការនៅក្នុងការិយាល័យរដ្ឋបាល និងគ្រឹះស្ថានអប់រំ... អ្នកទាំងអស់នោះសុទ្ធតែជាមនុស្សដែលបានទទួលការអប់រំកម្រិតបរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ទាំងអស់។ សារុបយ៉ាងខ្លីមក អ្នកនិយាយទាំងអស់សុទ្ធសឹងតែជាបញ្ញវន្ត។

ការសិក្សានេះតម្រូវអោយអ្នកនិយាយម្នាក់ៗអានគូអប្បបរមាទាំងអស់ដែលបានរៀបចំរួចជាស្រេច អានពាក្យនៅក្នុងបរិបទផ្លូវការ

អានអត្ថបទខ្លី ឆ្លើយនឹងកម្រងសំណួរដែលចំនួនពាក្យមានលើសពី ២០០០។ បន្ទាប់មក យើងក៏យកគំនិតរបស់អ្នកនិយាយ ដោយថតសំឡេងភាសាខ្មែររបស់ពួកគាត់ ទាំងក្នុងបរិបទផ្លូវការ និងបរិបទមិនផ្លូវការ។

## ២.១.១. លទ្ធផល

ពាក្យថា "និយាយច្បាស់" មានន័យជាភាសាអង់គ្លេសថា "To Speak Clearly"។ ពាក្យនេះសំដៅលើអ្វីដែលជារបៀបនិយាយមួយដែលគេចង់បាន និងអាចកំណត់បានថាជាភាសាខ្មែរស្តង់ដារ។ របៀបនិយាយនេះជាកម្រិតភាសាដែលគួរតែប្រើប្រាស់ក្នុងបរិបទផ្លូវការដូចជា ៖ បរិបទកិច្ចការរដ្ឋបាល វិទ្យុ ទូរទស្សន៍ និងការបង្រៀន។

ខាងក្រោមនេះជាសេចក្តីសង្ខេបលទ្ធផលនៃការស្រាវជ្រាវរបស់យើង។ ទិន្នន័យដែលបង្ហាញនៅខាងក្រោមគឺជាការកត់សូរបែបទូលាយ។ សម្រាប់ពេលនេះ យើងនៅមិនទាន់ត្រូវការសេចក្តីលម្អិតនោះទេ។

### ២.១.១.១. ព្យញ្ជនៈ

ការសិក្សាពីព្យញ្ជនៈរបស់យើងនៅទីនេះខុសប្លែកពីការសិក្សាដទៃ ដោយហេតុថាយើងមិនបានដាក់បញ្ចូលព្យញ្ជនៈធនិតក្នុងតារាងចំណាត់ថ្នាក់សូរព្យញ្ជនៈនោះទេ។ ព្យញ្ជនៈធនិតនៅក្នុងភាសាខ្មែរត្រូវបានវិភាគថាជាព្យញ្ជនៈផ្សំ។ ចំណុចគួរឲ្យកត់សម្គាល់មួយទៀត គឺយើងបានប្រើប្រាស់សញ្ញា [β̞] ដែលជាសញ្ញាសម្រាប់ព្យញ្ជនៈខ្យល់ត្រដុសបើកបបូរមាត់ទាំងពីរ ជំនួសអោយសញ្ញាដែលគេធ្លាប់ប្រើពីមុនមាន ៖ សញ្ញា [v] ដែលជាសញ្ញាសម្រាប់ព្យញ្ជនៈខ្យល់ត្រដុសបបូរមាត់ធ្មេញ ឬសញ្ញា [w] ដែលជាសញ្ញាសម្រាប់ព្យញ្ជនៈខ្យល់ត្រដុសបើករនាំងក្រអូមបបូរមាត់។

| | បបូរមាត់ | ធ្មេញ គន្លាក់ក្រអូម | ក្រអូម | រនាំងក្រអូម | ចន្លោះខ្សែសំឡេង |
|---|---|---|---|---|---|
| ព្យញ្ជនៈខ្យល់ស្ទះ | p b | t d | c | k | ʔ |
| ព្យញ្ជនៈច្រមុះ | m | n | ɲ | ŋ | |
| ព្យញ្ជនៈញ័រ | | r | | | |
| ព្យញ្ជនៈខ្យល់ត្រដុស | | s | | | h |
| ព្យញ្ជនៈខ្យល់ត្រដុសបើក | β̞ | | j | | |
| ព្យញ្ជនៈខ្យល់ត្រដុសបើកខាង | | l | | | |

### ២.១.១.២. ស្រៈទោល និងស្រៈផ្សំពីរ

ខុសពីលទ្ធផលនៃការវិភាគដទៃទៀត នៅក្នុងការសិក្សារបស់យើងនេះ យើងបានកំណត់យកប្រព័ន្ធស្រៈក្នុងភាសាខ្មែរដូចតទៅ ៖ ស្រៈទោលវែងចំនួន ១០ ស្រៈទោលខ្លីចំនួន ៨ (ស្រៈទោលខ្លីបិទមិនបានរាប់បញ្ចូលក្នុងប្រព័ន្ធសទ្ទតានោះទេ) ស្រៈផ្សំពីរវែងចំនួន ១០ (មិនមែនចំនួន ១៣ ឬ ១៤ នោះទេ) និងស្រៈផ្សំពីរខ្លីចំនួន ៣។ សារុបមកស្រៈទាំងអស់ក្នុងភាសាខ្មែរមានចំនួន ៣១។



## ក. គូអប្បបរមា ៖ ស្រៈទោលវែង / ស្រៈទោលខ្លី

| | | | |
|---|---|---|---|
| /eː/ ~ /e/: | គេង | គិញ | /keːɲ/ ~ /keɲ/ |
| /ɛː/ ~ /ɛ/: | ជែង | ចេញ | /cɛːɲ/ ~ /cɛɲ/ |
| /aː/ ~ /a/: | ចាប | ចាប់ | /caːp/ ~ /cap/ |
| /əː/ ~ /ə/: | ទើប | ទិព្វ | /təːp/ ~ /təp/ |
| /oː/ ~ /o/: | ពោត | ពត់ | /poːt/ ~ /pot/ |
| /ɔː/ ~ /ɔ/: | គក | កុក | /kɔːk/ ~ /kɔk/ |
| /ɒː/ ~ /ɒ/: | ចប | ចប់ | /cɒːp/ ~ /cɒp/ |

## ខ. គូអប្បបរមា ៖ ស្រៈបិទ / ស្រៈបើក

| | | | |
|---|---|---|---|
| /iː/ ~ /eː/: | ទី | ទេ | /tiː/ ~ /teː/ |
| /eː/ ~ /ɛː/: | មេឃ | មែក | /meːc/ ~ /mɛːc/ |
| /ɛː/ ~ /aː/: | តែម | កាម | /kɛːm/ ~ /kaːm/ |
| /ɨː/ ~ /əː/: | ឈឺ | ឈើ | /chɨː/ ~ /chəː/ |
| /uː/ ~ /oː/: | គូ | គោ | /kuː/ ~ /koː/ |
| /oː/ ~ /ɔː/: | គោ | គ | /koː/ ~ /kɔː/ |
| /ɔː/ ~ /ɒː/: | គ | ក | /kɔː/ ~ /kɒː/ |
| /e/ ~ /ɛ/ | គេច | កិច្ច | /kec/ ~ /kɛc/ |
| /ɛ/ ~ /a/: | ចេញ | ចាញ់ | /cɛɲ/ ~ /caɲ/ |
| /ə/ ~ /ɜ/: | ជិត | ចិត្ត | /cət/ ~ /cɜt/ |
| /o/ ~ /ɔ/: | ទុក | តុ | /tok/ ~ /tɔk/ |
| /ɔ/ ~ /ɒ/: | កុដិ | កត់ | /kɔt/ ~ /kɒt/ |

## ឃ. ស្រះផ្សំពីរខែង




| | | |
|---|---|---|
| /iɜ/: | ទា | /tiɜ/ |
| /ɨɜ/: | លឿន | /lɨɜn/ |
| /uɜ/: | គួរ | /kuɜ/ |
| /aɛ/: | តែ | /taɛ/ |
| /aɜ/: | បើ | /baɜ/ |
| /aɔ/: | តៅ | /taɔ/ |
| /oa/: | គាត់ | /koat/ |
| /ɛe/: | កើ្ដ | /kɛe/ |
| /oʊ/: | ដូរ | /doʊ/ |
| /ɜə/: | មឺុន | /mɜən/ |

## ខ. ស្រៈផ្សំពីរខ្លី




ពូក ពាក្យ ពាក់ : /pŭɜʔ/-/pĭɜʔ/-/pɛ̆aʔ/

យើងសង្កេតឃើញថា ចំនួនស្រៈទាំង ៣១ ដែលមាននៅក្នុងការបញ្ចេញសំឡេងដែលល្អ និងអាចទទួលយកបាននេះ គឺវាប្រហាក់ប្រហែលនឹងការបញ្ចេញសូរសំឡេងគ្រាមភាសាខ្មែរនៅភ្នំពេញដែរ។

យោងទៅតាមអ្នកនិយាយរបស់យើង របៀបនៃការនិយាយដ៏ច្បាស់មានដើមកំណើតនៅរាជធានីភ្នំពេញ។

## ២.១.២ ភាសាខ្មែរស្តង់ដារ និងមិនស្តង់ដារ

វចនានុក្រមនេះមានគោលបំណងបង្ហាញទាំងការបញ្ចេញសំឡេងភាសាខ្មែរស្តង់ដារ (របៀបផ្លូវការ) ទាំងការបញ្ចេញសំឡេងគ្រាមភាសាខ្មែរភ្នំពេញ (របៀបមិនផ្លូវការ)។ សំណួរមួយត្រូវបានចោទសួរឡើង ៖ តើភាសាខ្មែរស្តង់ដារ និងគ្រាមភាសាខ្មែរភ្នំពេញខុសគ្នាដូចម្តេចខ្លះ ?

បញ្ហានេះធ្លាប់ត្រូវបានគេលើកយកមកពិភាក្សាតាំងពីទសវត្សឆ្នាំ ៦០ មកម្ល៉េះ។ នៅសម័យនោះ លោក Noss (១៩៦៦) និង លោក Sakamoto (១៩៦៨) បានពណ៌នាអំពីភាសាខ្មែរស្តង់ដារ ដែលតាមពិតទៅជាការបញ្ចេញសូរសំឡេងរបស់បញ្ញវន្តដែលពណ៌នាដោយលោកស្រី Henderson (១៩៥២) លោក ឃួន សុខម្ភ (១៩៧០) និងលោក Gorgonijev (១៩៦៦) ថាខុសពីគ្រាមភាសាភ្នំពេញនៅត្រង់របៀបនៃការបញ្ចេញសូរ [r] ។

សព្វថ្ងៃនេះ របៀបនៃការបញ្ចេញសូរ [r] នៅតែអាចអោយយើងបែងចែកភាសាស្តង់ដារពីភាសាមិនស្តង់ដារ។ នៅក្នុងភាសាស្តង់ដារ មានការបញ្ចេញសូរ [r] ជាសូរចុងអណ្តាត។ បើគិតតាមបែបសូរវិទ្យា ការបញ្ចេញសូរ [r] ក្នុងភាសាមិនស្តង់ដារវិញ គឺជាការបង្កើតសូរដ៏ស្មុគស្មាញមួយ ដែលរួមបញ្ចូលចំណុចជាច្រើនដូចជា ៖

- ខ្យល់ផ្លុំ
- ការប្រែប្រួលកម្ពស់សូរ
- ស្រៈផ្សំនីយកម្ម
- កម្រិតបិទខ្ពស់ជាង

ឧទាហរណ៍ខាងក្រោមនេះនឹងបង្ហាញអំពីភាពខុសគ្នារវាងភាសាស្តង់ដារ និងគ្រាមភាសាភ្នំពេញ ទាក់ទងនឹងការបញ្ចេញសូរ [r] ៖

| **ពាក្យ** | **សូរស្តង់ដារ** | **សូរភ្នំពេញ** |
|---|---|---|
| ប្រាំ | pram | pe̤a̤m |
| ត្រង់ | trɑŋ | to̤ɑ̤ŋ |
| រយ | rɔːj | ɦɔ̤ːj |
| ស្រែ | sraɛ | sɛ̤ː |
| ស្រោម | sraɔm | sɔ̤ːm |
| ត្រើយ | traɜj | tɜ̤ːj |

### ២.១.៣. ទម្រង់ផ្សេងៗនៅក្នុងវចនានុក្រមនេះ

វចនានុក្រមនេះមានគោលបំណងបង្ហាញទាំងភាសាខ្មែរស្តង់ដារ ទាំងគ្រាមភាសាភ្នំពេញ។ ចំពោះគ្រប់ពាក្យទាំងអស់ យើងនឹងបង្ហាញការបញ្ចេញសូរសំឡេងតាមទម្រង់ផ្លូវការមុនគេ។ ទម្រង់បន្ទាប់ គឺការបញ្ចេញសូរសំឡេងតាមទម្រង់មិនផ្លូវការ។ ទម្រង់ចុងក្រោយបង្អស់ គឺជាទម្រង់មិនផ្លូវការជាងគេ។

ទាក់ទងនឹងប្រព័ន្ធនៃការកត់សូរដែលយើងបានប្រើប្រាស់នៅក្នុងវចនានុក្រមនេះវិញ យើងមានបំណងចង់អោយមានភាពងាយស្រួលក្នុងការបញ្ចេញសូរសំឡេង ហើយអោយអ្នកដែលមានភាសាកំណើតជាភាសាខ្មែរអាចស្តាប់យល់បានភ្លាមៗ។ ដូច្នេះ អ្នកដែលអានវចនានុក្រមនេះត្រូវមានចំណេះដឹងជាមូលដ្ឋានអំពីសញ្ញាសូរវិទ្យាអន្តរជាតិជាចាំបាច់។ ចំពោះការកត់សូរក្នុងវចនានុក្រមនេះ យើងមិនបានប្រើប្រាស់សញ្ញាសូរវិទ្យាឲ្យគ្រប់ទាំងអស់នោះទេ។ បើនិយាយម្យ៉ាងទៀត ប្រព័ន្ធនៃការកត់សូរដែលយើងប្រើប្រាស់ក្នុងវចនានុក្រមនេះ គឺនៅចន្លោះរវាងការកត់សូរបែបទូលាយ និងការកត់សូរបែបចង្អៀត។

ខាងក្រោមនេះ យើងនឹងបង្ហាញអំពីក្បួនច្បាប់មួយចំនួន ដែលអាចទាក់ទាញចំណាប់អារម្មណ៍អ្នកភាសាវិទ្យា និងអាចពន្យល់ពីប្រព័ន្ធនៃការកត់សូរដែលយើងយកមកប្រើប្រាស់។

#### ២.១.៣.១. សូរវិទ្យា និងការកត់សូរបែបទូលាយ

##### - ព្យញ្ជនៈចុងព្យាង្គគ្មានការបើក

ព្យញ្ជនៈខ្យល់ផ្ទុះ [p,t,k,c] និងព្យញ្ជនៈច្រមុះ [m,n,ɲ,ŋ] នៅខាងចុងព្យាង្គត្រូវបានបន្លឺ ប៉ុន្តែពុំមានការបើកណាមួយដែលអាចអោយឮការបន្លឺសូរទាំងនោះនៅខាងចុងព្យាង្គនោះទេ។ សញ្ញា [x̚] ដែលគេដាក់បន្ថែមលើព្យញ្ជនៈណាមួយនៅខាងចុងព្យាង្គដើម្បីបង្ហាញថាព្យញ្ជនៈនោះគ្មានការបើក គឺជាសញ្ញាដែលគេប្រើប្រាស់នៅក្នុងការ

កត់សូរបែបចង្អៀត ដើម្បីបង្ហាញដោយសេចក្ដីលម្អិតអំពីការបញ្ចេញសូរសំឡេងតាមទិដ្ឋភាពសូរវិទ្យា។ ដូច្នេះ យើងអាចយល់ហើយថាតាមពិតទៅ ពាក្យ "តុ" [tɔk] ត្រូវបញ្ចេញសូរសំឡេងថា [tɔk̚] ។

- **ច្រមុះនីយកម្ម**

ស្រៈបើកមធ្យម និងស្រៈបើកទូលាយ [ɛ,ɜ,ɔ,a,ɑ] សុទ្ធតែទទួលរងច្រមុះនីយកម្មនៅពេលដែលវានៅពីខាងមុខព្យញ្ជនៈច្រមុះ [ŋ] ។ ពាក្យ "ចុង" [cɔŋ] និងពាក្យ "ចង់" [cɑŋ] មានការបញ្ចេញសូរសំឡេងថា [cɔ̃ŋ] និង [cɑ̃ŋ] ។

- **មជ្ឈនីយកម្ម**

ស្រៈបើកមធ្យមមុខ [ɛ] តែងតែក្លាយជាស្រៈកណ្ដាល [ɛ̈] (មជ្ឈនីយកម្ម) ឬមានការបញ្ចេញសូរសំឡេងដូចស្រៈកណ្ដាល [ɜ] នៅពេលដែលវានៅបន្ទាប់ពីព្យញ្ជនៈក្រអូម [j]។ ពាក្យ "ស្រី" អាចមានការបញ្ចេញសូរសំឡេងបីយ៉ាង ៖ [srɛj] [srɛ̈j] [srɜj] ។

- **រនាំងក្រអូមនីយកម្ម**

ព្យញ្ជនៈខ្យល់ត្រដុសបើកខាង [l] តែងតែទទួលរងរនាំងក្រអូមនីយកម្ម នៅពេលដែលព្យញ្ជនៈនេះនៅបន្ទាប់ពីស្រៈបិទមធ្យមក្រោយ [o] ឬស្រៈបើកមធ្យមក្រោយ [ɔ] ។ ពាក្យ "កុរ" មានការបញ្ចេញសូរសំឡេងថា [kɔlˠ]។ ក្នុងបរិបទមិនផ្លូវការ ការបញ្ចេញសូរសំឡេងថា [kaɔ] ក៏មានឮច្រើនដែរ។

- **បបូរមាត់នីយកម្ម**

ព្យញ្ជនៈខ្យល់ស្ទះ [k] បានក្លាយជាព្យញ្ជនៈបបូរមាត់ ក្នុងករណីដែលព្យញ្ជនៈនេះនៅបន្ទាប់ពីស្រៈក្រោយបិទ [u,ʊ]។ ពាក្យ "មុខ"[mʊk] មានការបញ្ចេញសូរសំឡេងថា [mʊkʷ] ។

- **អឃោសៈកម្ម**

ព្យញ្ជនៈច្រមុះ [m, n, ɲ, ŋ] និងព្យញ្ជនៈខ្យល់ត្រដុស [l, j, β̞] បានក្លាយជាព្យញ្ជនៈអឃោសៈនៅពេលដែលព្យញ្ជនៈទាំងនេះនៅបន្ទាប់ពីព្យញ្ជនៈខ្យល់ស្ទះអឃោសៈ [p, t, c, k] ។ ពាក្យដូចជា "ក្នុង" [knɔŋ] ព្យាង្គ [pjiɜŋ] ធ្វើ [tβ̞ɘː] មានការបញ្ចេញសូរសំឡេងថា [khn̥ɔŋ] [phj̥iɜŋ] [thβ̞̥ɘː] ។

## ២.១.៣.២. សន្ទតាវិទ្យា និងការកត់សូរចង្អៀត

- **ព្យញ្ជនៈផ្សំ**

ក្នុងភាសាខ្មែរ ទម្រង់ព្យញ្ជនៈផ្សំមានបីប្រភេទដូចខាងក្រោម ៖

ក. ទម្រង់ព្យញ្ជនៈផ្សំ ព១+ព២ ឧទាហរណ៍ ពាក្យ "ស្រី" [srɛj]
ខ. ទម្រង់ព្យញ្ជនៈផ្សំ ព១+ ʰ +ព២ ឧទាហរណ៍ ពាក្យ "ផ្ទះ" [pʰtɛah]
គ. ទម្រង់ព្យញ្ជនៈផ្សំ ព១+ ᵊ +ព២ ឧទាហរណ៍ ពាក្យ "ប្ដី" [pᵊdɛj]

ថ្វីត្បិតតែយើងអាចទាយទុកជាមុនអំពីការបញ្ចេញសូរសំឡេងស្តង់ដារនៃព្យញ្ជនៈផ្សំ ដោយផ្អែកលើក្បួនច្បាប់មួយចំនួនបានក៏ពិតមែនក៏ប៉ុន្តែ ដើម្បីឲ្យអ្នកប្រើប្រាស់វចនានុក្រមនេះមានភាពងាយស្រួល យើងក៏បានជ្រើសរើសយកការកត់សូរបែបចង្អៀតយកមកប្រើប្រាស់ ។

- **ពាក្យដែលបញ្ចប់ដោយព្យញ្ជនៈខ្យល់ត្រដុសបើកបបូរមាត់**

នៅខាងចុងពាក្យ ព្យញ្ជនៈខ្យល់ត្រដុសបបូរមាត់ [β̞] មានទិដ្ឋភាពសូរវិទ្យាដូចខាងក្រោម ៖

ក. ពេលព្យញ្ជនៈ [β̞] នៅបន្ទាប់ស្រៈ [a, ɘ, ɜ] វាមានលក្ខណៈសូរវិទ្យាដូចស្រៈបិទកណ្ដាល [ɨ] ។ ឧទាហរណ៍ ពាក្យ "បាវ" [baβ̞] និងពាក្យ "នូវ" [nɘβ̞] មានការបញ្ចេញសូរសំឡេងថា [baɨ] និង [nɘɨ] ។

ខ. ពេលព្យញ្ជនៈ [β̞] នៅបន្ទាប់ពីស្រៈទោល និងស្រៈផ្សំពីរ

មួយចំនួនដូចជា [i ,ɪ ,iɜ ,aɛ] វាមានលក្ខណៈស្ងួរវិទ្យាដូចស្រៈ [ʊ] ។ ពាក្យ "ជ្រីវ" [criβ̞] និងពាក្យ "កែវ" [kaɛβ̞] មានការបញ្ចេញសូរសំឡេងថា [criʊ] និង [kaɛʊ] ។

ទោះបីជាយើងអាចទាយទុកជាមុនបានអំពីការបញ្ចេញសូរសំឡេងនៃព្យញ្ជនៈ [β̞] នេះថានឹងមានការបញ្ចេញសូរសំឡេងបែបណានៅក្នុងបរិបទណាក៏ដោយ ក៏យើងនៅតែជ្រើសរើសការកត់សូរបែបចង្អៀតយកមកប្រើប្រាស់ដើម្បីអោយអ្នកអានមានភាពងាយស្រួល។

## - ព្យញ្ជនៈខ្យល់ផ្ទុះ

ទោះបីជាគ្មានគម្លាតខុសគ្នារវាងព្យញ្ជនៈ [b]/[ɓ] និង [d]/[ɗ] ក៏ដោយ ក៏យើងបានសម្រេចប្រើប្រាស់សញ្ញាព្យញ្ជនៈ [ɓ] និង [ɗ] នៅពីខាងមុខស្រៈទោលខ្លីដែរ ដោយសារថាសូរទាំងពីរត្រូវបានបន្លឺឡើងជាព្យញ្ជនៈខ្យល់ផ្ទុះច្បាស់ណាស់នៅក្នុងបរិបទនេះ។

## - ស្រៈក្រោយបើកទូលាយ [ɑ, ɒ]

ស្រៈក្រោយបើកទូលាយត្រូវបានកត់សូរ ដោយផ្អែកលើការបញ្ចេញសូរសំឡេងរបស់វាផ្ទាល់។ ពេលដែលយើងកត់សូរ [ɑ] មានន័យថា វាជាស្រៈមិនបបូរមាត់ ហើយបើកត់សូរ [ɒ] វាជាស្រៈបបូរមាត់។ នៅក្នុងភាសាខ្មែរ ពុំមានភាពផ្ទុយគ្នាបែបសទ្ទតាវិទ្យារវាងស្រៈ /ɑ/ និងស្រៈ /ɒ/ នោះទេ ហើយយើងអាចទាយដឹងមុនថាស្រៈណាក្នុងចំណោមស្រៈទាំងពីរនឹងបន្លឺនៅក្នុងបរិបទណា ដោយផ្អែកលើក្បួនច្បាប់មួយចំនួន។ ក្បួនច្បាប់ទាំងនោះរួមបញ្ចូលកត្តាច្រើនណាស់ ដូចជា ការលើកដាក់សំឡេង ការសង្កត់សំឡេង រចនាសម្ព័ន្ធនៃព្យាង្គ បរិបទស្ងួរវិទ្យាជាដើម ហើយកត្តាទាំងអស់នេះជាផ្នែកមួយនៃការប្រែប្រួលសង្គមស្ងួរវិទ្យាឯណោះទេ។ ដូច្នេះហើយ ដើម្បីឲ្យអ្នកអានមានភាពងាយស្រួលក្នុងការអានពាក្យទាំងនេះ យើងក៏បានសម្រេចប្រើប្រាស់ការកត់ត្រាសូរទាំងពីរករណីនេះទៅតាមការបន្លឺរបស់វា។

- **ស្រៈផ្សំពីរ**

ដូចដែលយើងបានសរសេររៀបរាប់ពីខាងលើរួចមកហើយ នៅក្នុងភាសាខ្មែរស្តង់ដារ ស្រៈផ្សំពីរវែងមានចំនួន ១០ ហើយស្រៈផ្សំពីរខ្លីមានចំនួន ៣។ មិនមែនមានស្រៈផ្សំពីរវែង ១៣ ឬ ១៤ នោះទេ។ អ្នកអានវចនានុក្រមនេះអាចនឹងភ្ញាក់ផ្អើលមិនខាននៅពេលឃើញសញ្ញាសូរវិទ្យាដូចជា [ɛi,ai,aɨ](មើលទៅដូចស្រៈផ្សំពីរ)។ហេតុអ្វីបានជាយើងកត់សូររបៀបនេះ។ មូលហេតុគឺងាយយល់នោះទេ ៖ ដោយផ្អែកលើទិដ្ឋភាពសូរវិទ្យា ការផ្សំគ្នានៃសូរទាំងពីរនេះ គឺដូចជាស្រៈផ្សំពីរពិតៗ ប៉ុន្តែបើផ្អែកលើទិដ្ឋភាពសទ្ទតាវិទ្យាវិញ វាគឺជាបន្សំរវាងស្រៈមួយជាមួយនឹងព្យញ្ជនៈ [j] និង [ɟ] ទៅវិញទេ (Filippi និង Hiep, ២០០៦)។ ដូច្នេះហើយ ការកត់សូរបែបចង្អៀតសម្រាប់ពាក្យ "ថ្ងៃ" គឺ [thŋ̊ai] ប៉ុន្តែបើតាមទិដ្ឋភាពសទ្ទតាវិទ្យាវិញ ពាក្យនេះគេកត់សូរថា /tŋaj/។

## ២.១.៤. ការប្រើប្រាស់ប្រព័ន្ធអក្ខរវិធីសំណាង

តាមលោក M. Antelme (២០០២) មានអក្ខរវិធីសំណាងច្រើនដែលបានប្រើប្រាស់ដើម្បីកត់ត្រាភាសាខ្មែរ។ ប្រព័ន្ធអក្ខរវិធីសំណាងដែលយើងប្រើប្រាស់នៅក្នុងវចនានុក្រមនេះ គឺយកតាមប្រព័ន្ធអក្ខរវិធីសំណាងរបស់លោក Lewitz (១៩៦៩)។

អ្វីទៅជាអក្ខរវិធីសំណាង? ធ្វើអក្ខរវិធីសំណាងមានន័យថា ជំនួសសំណេរព្យញ្ជនៈនៃអក្ខរក្រមខ្មែរដែលមានដើមកំណើតពីអក្ខរក្រមសំស្ក្រឹតដោយប្រើប្រាស់ប្រព័ន្ធមួយដែលប្រើអក្សររ៉ូម៉ាំងដើម្បីបង្ហាញការបញ្ចេញសូរសំឡេងរបស់សំណេរព្យញ្ជនៈនីមួយៗរបស់ខ្មែរ ដែលមាននៅក្នុងភាសាសំស្ក្រឹត។

ឧទាហរណ៍ ៖ អក្សរ "ក" និង "គ" នៃភាសាខ្មែរមានទម្រង់ពីរខុសគ្នាមែន ប៉ុន្តែបើតាមទិដ្ឋភាពជាក់ស្តែងនៃសូរវិទ្យាវិញ ព្យញ្ជនៈទាំងពីរនេះគឺជាសូរព្យញ្ជនៈ [k] តែមួយប៉ុណ្ណោះ។ បើតាមទិដ្ឋភាពនៃភាសា

សំស្រ្កឹតវិញ អក្សរ "ក" មានការបញ្ចេញសូរសំឡេង [k] (អឃោសៈ) ចំណែកឯអក្សរ "គ" វិញមានការបញ្ចេញសូរសំឡេង [g] (ឃោសៈ)។ អក្ខរវិធីសំណាងដែលបានប្រើប្រាស់ក្នុងការកត់ត្រាសូរព្យញ្ជនៈទាំងពីរនេះ គឺ "ក" « k » និង "គ" « g » ។ ដោយមិនទាក់ទងអ្វីនឹងភាសាសំស្ក្រឹតនៅក្នុងភាសាខ្មែរបុរាណ ក៏មានលក្ខណៈផ្ទុយគ្នារវាងព្យញ្ជនៈឃោសៈ និងអឃោសៈដែរ p/b,t/d,c/ɟ,k/g ។ ប៉ុន្តែ បន្ទាប់ពីការធ្វើអឃោសកម្មនៃព្យញ្ជនៈ[bdɟg]មក នៅក្នុងភាសាខ្មែរបច្ចុប្បន្នមានតែព្យញ្ជនៈអឃោសៈ [ p t c k ] ទេ។ យើងអាចមើលឃើញរឿងនេះបាន ដោយសង្កេតទៅលើសំណេរ។ កត្តានេះជាមូលហេតុដែលនាំឲ្យអក្ខរវិធីសំណាងរឹតតែមានប្រយោជន៍សម្រាប់អោយអ្នកអានបានដឹងពីប្រវត្តិនៃភាសាខ្មែរ។

សារប្រយោជន៍របស់អក្ខរវិធីសំណាងមួយទៀត គឺបង្ហាញអំពីប្រវត្តិរបស់ពាក្យ។ ពាក្យដែលសរសេរថា "ពោធិ៍សាត់" មានការបញ្ចេញសូរសំឡេងថា [posat]។ ការកត់សូរមិនបានបង្ហាញអ្វីទាក់ទងនឹងន័យរបស់ពាក្យនេះទេ។ ផ្ទុយទៅវិញ អក្ខរវិធីសំណាងនៃពាក្យនេះ « bodhisat » អាចបញ្ជាក់ពីដើមកំណើតនៃពាក្យនេះបាន។

វចនានុក្រមនេះគ្រាន់តែជាការខិតខំប្រឹងប្រែងជាលើកដំបូងប៉ុណ្ណោះ។ នៅថ្ងៃអនាគត យើងនឹងមានគម្រោងកែសម្រួលជាថ្មី ដោយមានដាក់បញ្ចូលពាក្យថ្មីមកជាមួយដែរ។

អ្នកនិពន្ធវចនានុក្រមនេះសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់មិត្តភក្តិទាំងអស់ ដែលបានជួយគាំទ្រ និងកែលម្អកិច្ចការនេះ មានដូចជា លោក Michel Antelme លោក Olivier de Bernon លោក Steven Boswell លោក Philippe Delanghe និង លោកស្រី Anne Lemaistre។

# ឯកសារយោង

Antelme, M. R. 2002. “Note on the transliteration of Khmer”. Udaya, Number 3.

Filippi, J-M. 2002. « La description des dialectes du Khmer ». Actes du Congrès de l’Agence Universitaire Francophone.

Filippi, J-M. 2007. *Norme et phonétisme dans le Cambodge moderne*. Udaya. Number 4.

Filippi, J-M et Hiep, C. V. 2006. *Introduction to phonetics*. Phnom Penh, FUNAN. (In Khmer language).

Finot, L. 1902. « Notre transcription du cambodgien ». BEFEO, T. 2, PP. 1-15

Gorgonijev, Ju. 1966. *Grammatika khmerskogo jazika*. Moskva, Nauka.

Henderson, E.J.A. 1952. “The Main Features of Cambodian Pronunciation”. BSOAS, Vol. XIV: Part 1: 151-174.

Huffman, F.E. 1967. *An Outline of Cambodian Grammar*. Cornell University, PhD.

Huffman, F.E. 1970-a. *Modern Spoken Cambodian*. Cornell University, Southeast Asia Program.

Huffman, F.E. 1970-b. *Cambodian Writing System and Beginning Reader*. New haven, Yale University Press.

Khuon, S. 1970. *Système de la phonétique khmère*. Section de linguistique appliquée de la faculté des lettres et des sciences humaines de l’Université de Phnom Penh. (En langue Khmère).

Lewitz, Saveros, 1969. *Note sur la translittération du Cambodgien*, BEFEO, LV, Paris, PP. 163-169.

Martini, F. 1946. « Aperçu phonologique du cambodgien ». BSLP 42, Fascicule 1, No.124, PP. 112-131.

Maspero, G. 1915. *Grammaire de la langue khmère (Cambodgien)*. Paris, Imprimerie nationale.

Noss, R.B. 1966. “The treatment of /r/ in two modern Khmer dialects”. Studies in comparative Austro-Asiatic linguistics, Norman Zide (ed).

Sakamoto, Y. 1968. “The standard Khmer Language and its Phnom Penh Dialect”. Tônan ajia Kenkyû 6 - 2.

# Foreword

The writing of a Standard Khmer pronunciation dictionary raises a number of preliminary questions: is there an acknowledged standard Khmer pronunciation? What is it like? And where does it come from? It is necessary to add that we don't consider the concept of "standard language" in the usual meaning, namely as a set of precise normative rules. For us here "standard language" refers to the way Khmer is or should be spoken in a formal environment such as universities, schools, administration, media…

This set of questions has never been really seen as relevant and Khmer language was often seen as displaying a considerable unity in space. Such a unity could very well allow considering linguistic variation of secondary importance.

For instance, according to Huffman (1967): "The dialects of Cambodian are remarkably homogeneous, and the degree of dialect variation seems to be roughly comparable to that between the various dialects of American English. Even the dialects spoken in northeastern Thailand and western South Vietnam appear to be mutually comprehensible with the dialects spoken in Cambodia, the differences being perhaps on the order of those between British and American English."

The problem lies here in the high degree of ambiguity conveyed by notions such as "homogeneous" or "mutually comprehensible" (Filippi, 2007). In any case, there is no evidence to back Huffman's assertion, because apart from a limited number of surveys (Filippi, 2002) we do not have at our disposal any comprehensive description of Khmer language geographic variation.

# 1. The emergence of a standard Khmer pronunciation

## 1.1 Before the present time

From the 14th century onward, the local monastery was the only source of production of written documents. This one monastery - one peculiar script strategy resulted in an atomization. Each monastery had its own script rules based on the local pronunciation: there was no important religious center that could edict normative rules accepted by the others.

According to Maspéro (1915), who wrote the first Khmer language modern grammar, "Till now, the script has been submitted to the whims of the scribes who are considered in Cambodia as scholars."

Interestingly enough, even nowadays it is not uncommon to hear from elder people that they can only read *cbap* [codes prescribing moral behavior] from their own village monastery.

## 1.2 The first linguistic descriptions of Khmer language

There exists a number of linguistic descriptions dating back to the French Protectorate (1863 - 1953) and Sangkum Reastr Niyum (1955 - 1970). These various descriptions may or may not be a good approach to a Standard Khmer pronunciation, but at least to the way of speaking they are acknowledged as valuable.

Finot (1902) and Maspéro (1915) are of course full of interesting information, but they are absolutely mute as far as any localization is concerned, nor do they consider that one Khmer variety could be preferred to another one.

Martini's description (1946) is the first one to mention the local source of its description: Phnom Penh. This choice doesn't rely on the fact that Phnom Penh dialect would have been more prestigious than any other, but as Martini explains: "As a base for our description, we selected the Phnom Penh dialect. It stands in between the linguistically more conservative Battambang and the diphthongization of Cochinchina".

This is only partially true for 3 reasons:

a. At that time, Phnom Penh was a Chinese town and Tew Chiu Chinese was much more widely spoken than Khmer.

b. A closer examination of Martini's description leads us to suspect that the pronunciation he described seems more related to a provincial dialect (Kompong Spoeu?) as could be seen, for instance, from the absence of the diphthongization that characterizes central Khmer: for instance the word កោរ "to shave" is generally pronounced [kaɔ] in central Khmer but in a number of villages surrounding the town of Kompong Spoeu [koː]. The reason is obvious: the informants Martini worked with were very often monks coming from various parts of the country. Phnom Penh had become in the early 30s an important religious center with the creation in 1929 - 1930 of the Buddhist Institute.

c. It appears that Khmer script exerted an influence on Martini's or his informants' perception of Khmer language sounds. This is shown by the presence of velar consonants after front vowels and this is definitely not a central Khmer feature. For instance the word គេង "to sleep" is pronounced [keːɲ] and not [keːŋ] contrary to what the presence of the written final consonant ង (pronounced [ŋ] in other contexts) may suggest.

Martini's description is very typical of what was to be considered only a few years later as a Standard Khmer pronunciation, that is:

- The language of an important scholar, generally from the Buddhist Institute
- A strong influence of the Khmer script on pronunciation

## 1.3 The slow emergence of a norm

In the early 1950s, a standard Khmer language slowly emerged. The notion of "good pronunciation" had become a social reality. As a matter of fact, there was still no such a thing as a text prescribing the proper way to pronounce.

What is interesting is that this new Standard Khmer was based on the pronunciation of eminent academics and scholars who in turn had to try hard to put aside the most salient features of their own provincial dialect in order to promote a Khmer script based pronunciation. The result is a

rather disembodied level of language.

The best example of such an attitude is E. Henderson's (1952) "The main features of Cambodian pronunciation".

According to Henderson's Khmer vowel treatment, Khmer vocalism would be structured on the following opposition: modal voice / breathy voice opposition.

This had actually been the case a few centuries before. It is a part of the devoicing process that has affected Khmer language from the 14th century onward and it can be exemplified as follow, with the word "duck". The two subscript points indicate a breathy voice register.

| Period I | Period II | Period III |
|---|---|---|
| daː | d̤ɛ̤a̤ | tiɜ |

It simply means that a voiced consonant became unvoiced after having gone through a breathy voice register, all this provoking a change in the concerned vowels. We can still see the effects of this phenomenon called the Mon Khmer shift in the current Khmer vowel system if we examine its relationship to the script.

One thing is sure: apart from a small number of peripheral dialects, nowadays or in the early 50s, there is no central Khmer dialect that could be analyzed as structured by a modal / breathy voice opposition.

Henderson was totally right from a historical point of view; the only problem was that the Khmer language she described had nothing to do with any existing Khmer pronunciation in the 50s. There is a natural explanation if we consider that her main informant was Keng Vannsak. Keng Vannsak was a high level Cambodian intellectual who was very much concerned with language, literature and civilization questions. He would himself write later "Principles of Creating New Words". As an informant, Keng Vannsak didn't speak at all his own Kompong Chhnang dialect, but derived his own highly standard pronunciation from Khmer script.

Another example comes from Khuon Sokhampu who wrote his PhD thesis in Berlin in 1967. He analyzed Khmer pronunciation on the base of recordings of the supreme patriarch of the Buddhist Mohanikaj

Order, Chuon Nath. Yuriy Gorgonijev wrote in 1966 his Khmer language grammar and, his only informant was the late professor Long Seam.

In some sense, it is fascinating to consider that this highly idealized Khmer language based on the pronunciation of an academic authority had but little if any counterpart in reality.

In conclusion we can consider that Standard Khmer, or at least the level of language that was considered to play that part, had absolutely no identifiable geographical base. All the descriptive surveys published in these years display the same characteristic: One informant, generally a prominent scholar, whose pronunciation was based on script.

## 2. Contemporary Khmer

On April 19, 1975, Phnom Penh and all the towns of Cambodia were totally emptied of their inhabitants. The whole urban population was sent to the countryside and education was banned. With the fall of the Khmer Rouge regime in 1979, the situation came slowly back to normal and urban life was progressively restored.

In the context of the reconstruction in the early 1980s, it may appear surrealistic to evoke a standard language.

Under the Khmer Rouge rule, people had greatly suffered too much in the most intimate aspects of their lives: language, for instance, was under constant supervision; some people’s way of speaking clearly designated them as class enemies.

In the years that followed the fall of the Khmer Rouge regime till today, there was no text, no recommendation, and no mention of what a standard language pronunciation should be, but with the renaissance of the towns, a standard pronunciation was slowly emerging.

### 2.1 Surveying Standard Khmer pronunciation

At the time we began collecting data for this Khmer pronouncing dictionary, we carried out a survey about testing the “desirable and less desirable ways of speaking”.

We selected a number of persons working in fields including administration and education. All of them held degrees such as BA, MA, in short, they were educated people. The survey consisted in having

the informant reading minimal pairs, words in a formal context and small passages, answering a questionnaire of more than 2000 words, and collecting informants' opinions on recordings of Khmer language in formal and less formal contexts.

### 2.1.1 The results

One recurring theme was *"nijiey cbah"*, meaning literally "to speak clearly" and it refers to is a desirable way of speaking that could be identified as standard Khmer. It corresponds roughly to the language level that should be used in formal contexts such as administration, radio, television and teaching.

The following is an overview of our results. The data is displayed in a broad transcription. For the present purpose, we don't really need to take smaller details into consideration.

#### 2.1.1.1 Consonants

Contrary to a number of other approaches, we do not include the "aspirated consonants" in the chart, as they consist in fact of two elements (consonant clusters). Another noticeable point is that we use the symbol of a bilabial approximant [β̞] instead of the usual labiodental voiced fricative [v] or the voiced labialized velar approximant [w].

| | Labial | Dental | Palatal | Velar | Glottal |
|---|---|---|---|---|---|
| Plosive | p b | t d | c | k | ʔ |
| Nasal | m | n | ɲ | ŋ | |
| Trill | | r | | | |
| Fricative | | s | | | h |
| Approximant | β̞ | | j | | |
| lateral approximant | | L | | | |

### 2.1.1.2 **Vowels and diphthongs**

As far as the vowels are concerned, different from a number of other analysis, we determined ten long vowels; eight short vowels, (close short vowels are not phonemically relevant), ten long diphthongs and not thirteen or fourteen, and finally three short diphthongs; altogether thirty one distinctive units.

#### 2.1.1.2.1 **vowels**




Minimal pairs: long vs short vowels

| | | | | | |
|---|---|---|---|---|---|
| /eː/ ~ /e/: | គេង | to sleep | គិញ | detective | /keːɲ/ ~ /keɲ/ |
| /ɛː/ ~ /ɛ/: | ជែង | to win | ចេញ | to go out | /cɛːɲ/ ~ /cɛɲ/ |
| /aː/ ~ /a/: | ចាប | sparrow | ចាប់ | to catch | /caːp/ ~ /cap/ |
| /əː/ ~ /ə/: | ទើប | just | ទិព្វ | divine | /təːp/ ~ /təp/ |
| /oː/ ~ /o/: | ពោត | corn | ពត់ | to bend | /poːt/ ~ /pot/ |
| /ɔː/ ~ /ɔ/: | គក | kind of rooster | កុក | heron | /kɔːk/ ~ /kɔk/ |
| /ɒː/ ~ /ɒ/: | ចប | hoe | ចប់ | to end | /cɒːp/ ~ /cɒp/ |

Minimal pairs: close vs open

| | | | | | |
|---|---|---|---|---|---|
| /iː/ ~ /eː/: | ទី | place | ទេ | negative part | /tiː/ ~ /teː/ |
| /eː/ ~ /ɛː/: | មេឃ | sky | មក | branch | /meːc/ ~ /mɛːc/ |
| /ɛː/ ~ /aː/: | គែម | edge | កាម | desire | /kɛːm/ ~ /kaːm/ |
| /ɨː/ ~ /əː/: | ឈឺ | sick | ឈើ | wood | /chɨː/ ~ /chəː/ |
| /uː/ ~ /oː/: | គូ | pair | គោ | cow | /kuː/ ~ /koː/ |
| /oː/ ~ /ɔː/: | គោ | cow | គ | mute | /koː/ ~ /kɔː/ |
| /ɔː/ ~ /ɒː/: | គ | mute | ក | neck | /kɔː/ ~ /kɒː/ |
| /e/ ~ /ɛ/: | គេច | to escape | កិច្ច | task | /kec/ ~ /kɛc/ |
| /ɛ/ ~ /a/: | ចេញ | to go out | ចាញ់ | to loose | /cɛɲ/ ~ /caɲ/ |
| /ə/ ~ /ɜ/: | ជិត | near | ចិត្ត | feeling | /cət/ ~ /cɜt/ |
| /o/ ~ /ɔ/: | ទុក | to put | តុ | table | /tok/ ~ /tɔk/ |
| /ɔ/ ~ /ɒ/: | កុដិ | cell | កត់ | to note | /kɔt/ ~ /kɒt/ |

#### 2.1.1.2.2 **Diphthongs**

Long diphthongs



| | | | |
|---|---|---|---|
| /iɜ/: | ទា | /tiɜ/ | duck |
| /ɨɜ/: | លឿន | /lɨɜn/ | fast |
| /uɜ/: | គួរ | /kuɜ/ | ought to |
| /aɛ/: | តែ | /taɛ/ | only |
| /aɜ/: | បើ | /baɜ/ | if |
| /aɔ/: | តោ | /taɔ/ | lion |
| /oa/: | គាត់ | /koat/ | he |
| /ɛe/: | កេរ្តិ៍ | /kɛe/ | fame |
| /oʊ/: | ដូរ | /doʊ/ | to change |
| /ɜə/: | ម៉ឺន | /mɜən/ | 10000 |

Short diphthongs




ពួក group ពាក្យ word ពាក់ to carry : /pŭɜʔ/-/pĭɜʔ/-/pĕaʔ/

It is not difficult to see that the "good pronunciation" underlying these thirty one distinctive units is almost equivalent to the Phnom Penh dialect.

The current Standard Khmer, according to our informants "a clear way of speaking", has its origins in the Phnom Penh dialect.

### 2.1.2 Standard versus non standard

This dictionary being about both standard Khmer (formal style) and Phnom Penh dialect (casual style), it is interesting to consider the way the standard and non standard dialects differ from each other.

This has been a much debated question since the early 1960s. Noss (1966) and Sakamoto (1968) opposed the then Standard Khmer language, in fact the strongly idealized prominent scholars based pronunciation Henderson (1952), Khuon Sokhampu (1970), Gorgonijev (1966), to the then Phnom Penh dialect on the base of the local treatment of the "r".

Nowadays, the use of the "r" allows distinguishing a formal level of speech from a non-formal one. Phonetically, the non-formal variant is a complex realization that involves:

- Breathy voice
- Pitch variation
- Diphthongization
- A higher degree of closure

A few examples are given in the table below

| Khmer script | Standard pronunciation | Non standard | Meaning |
|---|---|---|---|
| ប្រាំ | Pram | pe̤a̤m | Five |
| ត្រង់ | trɑŋ | to̤ɑ̤ŋ | Right |
| រយ | rɔːj | ɦɔ̤ːj | Hundred |
| ស្រែ | sraɛ | sɛ̤ː | Rice field |
| ស្រោម | sraɔm | sɔ̤ːm | Envelope |
| ត្រើយ | traɜj | tɜ̤ːj | Shore |

### 2.1.3 Displaying

The dictionary aims to display both Khmer standard form and Phnom Penh casual form. We display first the most formal forms followed by casual pronunciations, the last one being the most casual.

The transcription system we devised was intended to display pronounceable words. This implies of course a basic knowledge of the International Phonetic Alphabet (IPA). However our transcription is not fully comprehensive from a phonetic point of view. In other words, the system we used stands between a broad and a narrow one.

We indicate below a number of rule governed features that may have some interest to the linguist.

#### 2.1.3.1 Phonetics and broader transcription

- **No audible release**

The final plosives [p, t, k, c] and the nasal [m, n, ɲ, ŋ] are pronounced without any audible release. The following symbol [x̚] should be used in a narrow transcription. For instance the word តុ [tɔk] is in fact pronounced [tɔk̚]

- **Nasalization**

The open-mid and open vowel [ɛ, ɜ, ɔ, a, ɑ] are strongly nasalized in front of [ŋ]. The words ចុង [[cɔŋ] and ចង់  [cɑŋ] are pronounced [cɔ̃ŋ] and [cɑ̃ŋ]

- **Centralization**

The front close-mid vowel [ɛ] is very often centralized [ɛ̈] or pronounced just like the central vowel [ɜ] when followed by the palatal approximant [j]. The word ស្រី can be pronounced in the following three ways: [srɛj], [srɛ̈j] and [srɜj]

- **Velarization**

The lateral approximant [l] is always velarized after a close-mid [o] or open-mid [ɔ] back vowel. The following word កុល is pronounced [kɔlˠ]. The casual pronunciation [kaɔ] is very common too.

- **Labialization**

The velar plosive [k] is strongly labialized after the back close vowels [u, ʊ]. The word មុខ [mʊk] is pronounced [mʊkʷ].

- **Devoicing**

The nasal consonants [m, n, ɲ, ŋ] and the ap p roximants [l, j, β̩] are devoiced after the voiceless plosives [p, t, c, k]. The following words: ក្នុង [knɔŋ] ព្យាង្គ [pjiɜŋ] ធ្វើ [tβ̩əː] are pronounced [kʰn̥ɔŋ] [pʰj̥iɜŋ] [tʰβ̩̊əː].

### 2.1.3.2 Phonemic and narrower transcription

- **Consonant clusters**

In Khmer, there are three kinds of consonant clusters:

a. C1C2. ស្រី [srɛj]

a. C1ʰC2 ផ្ទះ [pʰtɛah]

a. C1ᵊC2 ប្ដី [pᵊdɛj]

Even if the standard pronunciation of consonant clusters is rule predictable, In order to make the user’s task easier, we opted for a narrow phonetic transcription.

- **Word ending bilabial approximant**

At the end of a word, the bilabial approximant [β̩] has the following phonetic realizations:

a. After the vowels [a, ə, ɜ], it is the phonetic equivalent of the central closed vowel [ɨ]. For instance the words [baβ̩] and [nəβ̩] are pronounced [baɨ] and [nəɨ].

b. After the vowels and the diphthongs [i, ɪ, iɜ, aɛ] it is the equivalent of the vowel [ʊ]. The words ជ្រីវ [criβ̞] and កែវ [kaɛβ̞] are pronounced [criʊ] and [kaɛʊ].

Although these realisations are predictable, we nevertheless decided to use a narrow transcription to facilitate the reader's task.

- **Implosive consonants**

Although there is no distinctive opposition between [b] / [ɓ] and [d] / [ɗ], we decided to use the [ɓ] and [ɗ] symbols in front of short vowels as the two sounds are clearly implosive in this context.

- **The back open vowel [ɑ, ɒ]**

The back open vowel is transcribed according to its pronunciation: either [ɑ] (non labial) or [ɒ] (labial). There is of course no distinctive opposition between [ɑ] and [ɒ] and their occurrence can be predicted with a number of rules. But 1, these rules involve many prosodic and segmental parameters such as stress, syllabic structure, phonetic environment and 2, they are partly subject to sociolinguistic variation.
In order to make the reader's task easier, we transcribed the two variants.

- **Diphthongs**

We wrote above that there are ten long and three short diphthongs in Standard Khmer and not thirteen or fourteen. The dictionary user may be then surprised to read the following symbol sequences: [ɛi, ai, aɨ]. The reason is simple: from a phonetic point of view, these combinations sound like real diphthongs, but phonologically they are vowels + [j] and [ɨ̯] (Filippi and Hiep, 2006). For instance, according to its pronunciation, the word ថ្ងៃ can be accurately transcribed [t$^{h}$ŋ̊ai] but its representation in terms of functional or distinctive units (phonology) will be /tŋaj/.

## 2.1.4 The transliteration system

There exists a number of transliteration systems (Antelme, 2002). The one we use here has been devised by Lewitz (1969).

Transliteration means here to replace Khmer script, derived from a Sanskrit Brahmi alphabet, by a Romanized system that indicates the pronunciation each letter has in Sanskrit.

For example, the two Khmer letters ក and គ differ in shape, but are both currently pronounced [k]. In Sanskrit ក is pronounced [k] (voiceless) and គ is pronounced [g] (voiced). The transliterated values of the two consonants are as follows: ក ”k” and គ “g”. Independently from Sanskrit, there was also in Old Khmer a distinctive opposition between voiced and voiceless consonants p/b t/d c/ɟ k/g (currently pronounced [p t c k] as the former voiced consonants are now voiceless) and this is one reason why transliteration may be useful: to provide the reader with data related to the history of the language.

Another reason for using transliteration is that the transliterated forms may be helpful to understand the etymology of the word. For instance the following word ពោធិ៍សាត់ is pronounced [posat] but its transliterated form “bodhisat“allows us to better understand its etymological meaning.

This dictionary is but a first attempt. In the future, we plan more comprehensive versions.

The authors would like to thank their various friends who contributed to this work: Michel Antelme, Olivier de Bernon, Steven Boswell, Philippe Delanghe and Anne Lemaistre.

# References

Antelme, M. R. 2002. “Note on the transliteration of Khmer”. Udaya, Number 3.

Filippi, J-M. 2002. « La description des dialectes du Khmer ». Actes du Congrès de l’Agence Universitaire Francophone.

Filippi, J-M. 2007. *Norme et phonétisme dans le Cambodge moderne*. Udaya. Number 4.

Filippi, J-M et Hiep, C. V. 2006. *Introduction to phonetics*. Phnom Penh, FUNAN. (In Khmer language).

Finot, L. 1902. « Notre transcription du cambodgien ». BEFEO, T. 2, PP. 1-15

Gorgonijev, Ju. 1966. *Grammatika khmerskogo jazika*. Moskva, Nauka.

Henderson, E.J.A. 1952. “The Main Features of Cambodian Pronunciation”. BSOAS, Vol. XIV: Part 1: 151-174.

Huffman, F.E. 1967. *An Outline of Cambodian Grammar*. Cornell University, PhD.

Huffman, F.E. 1970-a. *Modern Spoken Cambodian*. Cornell University, Southeast Asia Program.

Huffman, F.E. 1970-b. *Cambodian Writing System and Beginning Reader*. New haven, Yale University Press.

Khuon, S. 1970. *Système de la phonétique khmère*. Section de linguistique appliquée de la faculté des lettres et des sciences humaines de l’Université de Phnom Penh. (En langue Khmère).

Lewitz, Saveros, 1969. *Note sur la translittération du Cambodgien*, BEFEO, LV, Paris, PP. 163-169.

Martini, F. 1946. « Aperçu phonologique du cambodgien ». BSLP 42, Fascicule 1, No.124, PP. 112-131.

Maspero, G. 1915. *Grammaire de la langue khmère (Cambodgien)*. Paris, Imprimerie nationale.

Noss, R.B. 1966. “The treatment of /r/ in two modern Khmer dialects”. Studies in comparative Austro-Asiatic linguistics, Norman Zide (ed).

Sakamoto, Y. 1968. “The standard Khmer Language and its Phnom Penh Dialect”. Tônan ajia Kenkyû 6 - 2.

# Avant-propos

La réalisation d'un dictionnaire de de la prononciation  du Khmer Standard soulève un certain nombre de questions préliminaires : le Khmer Standard a-t-il une prononciation particulière? Quelle est–elle? Quelle est son origine?

La notion de « langue standard » n'est pas prise ici dans le sens étroit qu'une tradition bien établie a conféré à ce terme, à savoir un ensemble de règles normatives. Pour nous, « langue Standard » réfèrera à la façon dont le Khmer est, ou devrait être, parlé dans des environnements formels tels que l'éducation, l'administration, les média, etc.

La pertinence de ces questions n'a jamais été vraiment prise en compte car le Khmer a souvent été caractérisé comme présentant une remarquable unité dans l'espace et donc peu sujet à une variation géolinguistique conçue de facto comme secondaire.

Ainsi, d'après Huffman (1967) : « Les dialectes du Cambodgien sont remarquablement homogènes et le degré de variation dialectale semble à peu près comparable à celui de l'Anglais américain. Même les dialectes parlés dans le Nord-Est de la Thaïlande et le Sud-Ouest du Vietnam semblent mutuellement compréhensibles avec les dialectes parlés au Cambodge, les différences étant peut-être de l'ordre de celles qui existent entre l'Anglais britannique et l'Anglais américain »

Le problème réside ici dans le haut degré d'ambiguïté afférent aux termes « homogènes » et « mutuellement compréhensifs » (Filippi, 2007). En tout état de cause, les affirmations de Huffman ne reposent sur aucune preuve tangible car, à l'exception d'un petit nombre d'études dialectales (Filippi, 2002), il n'existe aucune description digne de ce nom de la variation géolinguistique de la langue Khmère.

# 1. L’émergence d’une prononciation standard du Khmer

## 1.1 Avant l’époque moderne

Depuis le 14ème siècle et jusqu’à il y a peu, chaque monastère a été quasiment l’unique source de production d’écrits. Le fait que chaque monastère possède ses propres règles orthographiques basées sur la prononciation locale s’est traduit en une conception strictement locale de la norme.Cette atomisation reposait sur le fait qu’aucun centre religieux n’avait la capacité d’édicter une norme susceptible d’être adoptée par les autres.

Selon Maspéro (1915) qui est l’auteur de la première grammaire moderne du Khmer : «L’orthographe, jamais fixée jusqu’ici, est restée soumise aux fantaisies des scribes qui constituent au Cambodge la classe lettrée ».

Encore aujourd’hui, il est fréquent d’entendre des villageois déclarer qu’ils ne peuvent lire que les cbap (codes de conduite morale) de la pagode de leur village.

## 1.2 Les premières description linguistiques du Khmer

